# ឯកសារសង្ខេបអំពីដៃគូអនុវត្តជាយុទ្ធសាស្ត្រ
# ផ្នែកអំពើហិង្សាទាក់ទងនឹងយេនឌ័រ

## សង្ខេបគម្រោង

គម្រោងលទ្ធភាពទទួលបានយុត្តិធម៌សម្រាប់ស្ត្រីរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ (GBV) និងជនមានពិការភាព មានគោលបំណងធ្វើឱ្យប្រសើរឡើងនូវលទ្ធភាពទទួលបានយុត្តិធម៌សម្រាប់ស្ត្រីមាន និងមិនមានពិការភាព រងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ ដែលពួកគេមិនមានលទ្ធភាពទទួលបានជំនួយផ្នែកច្បាប់។ គម្រោងក៏នឹងផ្តោតលើការបង្កើនលទ្ធភាពទទួលបានយុត្តិធម៌សម្រាប់ស្ត្រីដែលមានពិការភាពដែលទទួលរងនូវអំពើហិង្សាទាក់ទងនឹងយេនឌ័រ ដែលជាក្រុមជនងាយរងគ្រោះ ហើយមិនមានលទ្ធភាពទទួលបានជំនួយផ្នែកច្បាប់។

គម្រោងនេះនឹងផ្តល់ការប្រឹក្សាយោបល់ផ្នែកច្បាប់ ផ្តល់ជំនួយផ្នែកច្បាប់ និងការគាំទ្រផ្នែកសង្គមផ្សេងៗ។ ជាងនេះទៀត គម្រោងនេះនឹងពង្រឹងសមត្ថភាពមន្ត្រីរដ្ឋាភិបាលក្នុងការដោះស្រាយបញ្ហាហិង្សាទាក់ទងនឹងយេនឌ័រ និងកសាងចំណេះដឹងផ្នែកយេនឌ័រនៅសហគមន៍។ តាមរយៈការផ្តល់ជាសិក្ខាសាលាដល់មន្ត្រីរដ្ឋាភិបាល អាជ្ញាធរមូលដ្ឋាន (ប៉ូលីស) និងបុគ្គលិកផ្នែកច្បាប់ គម្រោងនឹងពង្រឹងគុណភាពសេវាសម្រាប់ស្ត្រី រងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ ដូច្នេះពួកគាត់នឹងទទួលបាននូវការគាំទ្រផ្នែកសង្គម និងផ្នែកច្បាប់ដែលពួកគាត់ចង់បានកាន់តែប្រសើរ។

## លទ្ធផលរំពឹងទុករបស់គម្រោង

១.បង្កើនការផ្តល់សេវាផ្នែកច្បាប់ដល់ស្ត្រីរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ តាមរយៈជំនួយផ្នែកច្បាប់ និងសេវាគាំទ្រផ្សេងទៀត ដូចជា៖ ផ្តល់ជំនួយនិងប្រឹក្សាផ្នែកច្បាប់ដល់ជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ ផ្តល់ការគាំត្រផ្នែកសង្គម បង្កើតប្រព័ន្ធទិន្នន័យ និងប្រពន្ធ័គ្រប់គ្រងករណី។

២. ធ្វើឱ្យប្រសើរឡើងនូវសមត្ថភាពរបស់មន្ត្រីរដ្ឋាភិបាលក្នុងការដោះស្រាយអំពើហិង្សាទាក់ទងនឹងយេឌ័រ និងអប់រំសហគមន៍ឱ្យយល់ដឹងពីហិង្សាទាក់ទងនឹងយេនឌ័រ។ ដើម្បីសម្រេចបានចំណុចនេះគឺ៖

- បង្កើតឯកសារអប់រំ វីដេអូអប់រំពីអំពើហិង្សាទាក់ទងនឹងយេនឌ័រសម្រាប់សហគមន៍
- រៀបចំវេទិកាអំពីហិង្សាទាក់ទងយេនឌ័រ ដូចជាទិវាអន្តរជាតិនារី និងយុទ្ធនាការ១៦ថ្ងៃបញ្ឈប់អំពើហិង្សាលើស្ត្រី
- រៀបចំយុទ្ធនាការនានាពាក់ព័ន្ធនឹងអំពើហិង្សាលើស្ត្រីនិងអំពីសិទ្ធិរបស់ជនមានពិការភាពនៅតាមសហគមន៍
- រៀបចំវគ្គបណ្តុះបណ្តាល ដល់មន្ត្រីកិច្ចការសង្គម អំពីអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងបណ្តាញជនមានពិការភាព

- និង បង្កើតបណ្ដាញក្រុមការងារឆ្លើយតបអំពើហិង្សាទាក់ទងនឹងយេនឌ័រនៅថ្នាក់ស្រុក២បន្ថែមទៀត ។

៣. បង្កើនការសម្របសម្រួល និងពង្រឹងយន្តការក្នុងចំណោមអ្នកពាក់ព័ន្ធ ដើម្បីឱ្យពួកគាត់ធ្វើអន្តរាគមន៍ប្រកបដោយគុណភាព និងប្រសិទ្ធភាពចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រដែលកើតមានឡើងនៅក្នុងខេត្តគោលដៅ។ ដើម្បីសម្រេចបាននូវលទ្ធផលនេះគឺ៖

- រៀបកិច្ចប្រជុំចាំត្រីមាសជាមួយក្រុមការងារឆ្លើយតបអំពើហិង្សាទាក់ទងនឹងយេនឌ័រនៅក្នុងស្រុកគោលដៅ
- រៀបចំកិច្ចប្រជុំប្រចាំឆមាសជាមួយក្រុមប្រឹក្សាឃុំដើម្បីគៀងគរ និងលើកផែនការថវិកាឃុំសង្កាត់។
- រៀបចំកិច្ចប្រជុំប្រចាំឆមាសជាមួយក្រុមប្រឹក្សាឃុំក្នុងការរៀបចំបន្ទប់ដាច់ដោយឡែកសម្រាប់ប្រឹក្សាយោបល់ដល់ជនរងគ្រោះដោយសារអំពើហិង្សាទាក់ទងនឹងយេនឌ័រ

**សកម្មភាពសំខាន់ៗ**

សកម្មភាពសំខាន់ដែលLACនឹងអនុវត្ត រួមមាន៖

- ធ្វើការផ្សព្វផ្សាយ សហការជាមួយប៉ូលីស និងតុលាការដើម្បី ផ្ដល់ដល់ដំណើរការស៊ើបអង្កេតរឿងក្ដី និងនីតិវិធីតុលាការ បញ្ជូនកូនក្ដីទៅរកជំនាញ ដោយផ្អែកលើជំនាញរបស់អង្គការមិនមែនរដ្ឋាភិបាលផ្សេង។ រក្សាទំនាក់ទំនងជាមួយអាជ្ញាធរមូលដ្ឋាន ជាមួយមេធាវីរបស់LAC។
- ធ្វើការសហការណ៍យ៉ាជិតស្និទ្ធិជាមួយអាជ្ញាធរមូលដ្ឋាន និងអ្នកដឹកនាំក្នុងសហគមន៍ដើម្បីផ្ដល់ការបណ្ដុះបណ្ដាលច្បាស់លាស់ អំពីហិង្សាទាក់ទងនឹងយេនឌ័រ ហើយរៀបចំធ្វើការផ្សព្វផ្សាយដើម្បីលុបបំបាត់នូវផ្នត់គំនិតសង្គម។
- ជម្រុញទំនាក់ទំនង និងកិច្ចសហកាជាមួយអាជ្ញាធរថ្នាក់ក្រោមជាតិ។

**អ្នកទទួលផល**

អ្នកទទួលផលដោយផ្ទាល់របស់គម្រោងមាន៖

- ស្ត្រីដែលមាន និមិនមានពិការភាពដែលជាជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ
- សមាជិកក្រុមការងារឆ្លើយតបអំពើហិង្សាទាក់ទងយេនឌ័រ ថ្នាក់ស្រុក និងខេត្ត
- ក្រុមការងារសង្គមថ្នាក់ខេត្ត និងបណ្ដាញជនមានពិការភាព
- អាជ្ញាធរពាក់ព័ន្ធថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ  និងមន្ត្រីផ្នែកច្បាប់ពាក់ពន្ធ័ ដូចជា ចៅក្រម និងព្រះរាជអាជ្ញា
- សង្គមទាំងមូលដែលនឹងទទួលបានអត្ថប្រយោជន៍ពីការបង្កើននៃការផ្សព្វផ្សាយអំពីអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងការគោរពសិទ្ធិស្ត្រីឱ្យកាន់តែប្រសើរ

**តំបន់គោលដៅ**

LAC នឹងអនុវត្តកម្មវិធីនេះនៅក្នុងខេត្តបីដូចខាងក្រោម។ LACជ្រើសរើសខេត្តទាំងនេះ ព្រោះរកឃើញថាតំបន់គោលដៅនេះត្រូវការជំនួយផ្នែកច្បាប់សម្រាប់ជនរងគ្រោះដោយសារអំពើហិង្សាផ្នែកយេនឌ័រ។

- ខេត្តសៀមរាប (ស្រុកអង្គរជុំ សូទ្រនិគមន៍ ក្រឡាញ់ និងវ៉ារិន)
- ខេត្តកំពង់ស្ពឺ (ស្រុកបរសេដ្ឋ ថ្ពង ច្បារមន ឱរ៉ាល់ និងស្រុកភ្នំស្រួច)
- ខេត្តកំពង់ចាម (ស្រុកកំពង់សៀម ជើងព្រៃ បាធាយ និងក្រុងកំពង់ចាម)

**ដៃគូអនុវត្តគម្រោង**

- ខេត្តសៀមរាប៖ មន្ទីរកិច្ចការនារី មន្ទីរសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា មន្ទីរពេទ្យបង្អែក អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ(CWCC) អង្គការចិត្តសង្គមអន្តរវប្បធម៌ (TPO) អង្គការជនពិការកម្ពុជា (CDPO) អង្គការ ADD និងអង្គការបន្ទាយស្រី
- ខេត្តកំពង់ស្ពឺ៖ មន្ទីរកិច្ចការនារី មន្ទីរសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា មន្ទីរពេទ្យបង្អែក អង្គការCWCC អង្គការ TPO អង្គការជនពិការកម្ពុជា និងអង្គការ ADD
- ខេត្តកំពង់ចាម៖ មន្ទីរកិច្ចការនារី មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មន្ទីរពេទ្យបង្អែក អង្គការCWCC អង្គការ TPO អង្គការជនពិការកម្ពុជា និងអង្គការ ADD

**រយៈពេលអនុវត្តគម្រោង**

ខែមីនា ឆ្នាំ២០២៤ ដល់មិថុនា ឆ្នាំ២០២៨

**ព័ត៌មានទំនាក់ទំនង**


| | |
|---|---|
| អង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា (LAC)<br>លោក រុន សារ៉ាយ<br>នាយកប្រតិបត្តិ<br>លេខទូរស័ព្ទ៖ (៨៥៥)១២ ៨៣៨ ៣៤១<br>អ៊ីម៉ែល៖ lacdirector@online.com.kh | កម្មវិធី ACCESS 2<br>លោកស្រី ប៊ូ មករា<br>ប្រធានផ្នែកអំពើហិង្សាទាក់ទងនឹងយេនឌ័រ (GBV)<br>ទូរស័ព្ទ៖ (៨៥៥) ១២ ៦៩៤ ៩៩៤<br>អ៊ីម៉ែល៖ makara.bou@access2cambodia.org |


គម្រោងនេះ ឧបត្ថម្ភដោយរដ្ឋាភិបាលអូស្ត្រាលីតាមរយៈកម្មវិធីសហប្រតិបត្តិការអូស្ត្រាលី-កម្ពុជាដើម្បីសេវាប្រកបដោយនិរន្តរភាព និងសមធម៌ - ដំណាក់កាលទី២ (ACCESS 2)។

ខែមីនា ឆ្នាំ២០២៤